# សាលាវិទ្យាល័យអន្តេវាសិកជនជាតិ ហ្វិញគឿង
# សាទរ និងអនុវត្តកសាងគម្រោង "សាលារៀនសុភមង្គល"

"សាលារៀនសុភមង្គល" គឺជាគំរោងដែលបានផ្តើមឡើងដោយអង្គការយូណេ-ស្កូ (UNESCO) ក្នុងឆ្នាំ២០១៨។ ហើយក៏ត្រូវបានក្រសួងអប់រំ និងបណ្តុះបណ្តាលវៀតណាមយើងចុះសម្រុង និងអនុវត្តនូវគម្រោងនេះចាប់តាំងពីឆ្នាំ២០១៩ ដើម្បីជំរុញភាពរីករាយ និងការអភិវឌ្ឍន៍ទូលំទូលាយរបស់សិស្សានុសិស្ស។ គោលបំណងរបស់គំរោងនេះ គឺបង្កើតបរិយាកាសសិក្សាដែលគ្រូបង្រៀន សិស្សានុសិស្ស និងមាតាបិតា មានអារម្មណ៍សប្បាយ រីករា-យ ក្នុងដំណើរការអប់រំ។ នេះក៏ជាទីកន្លែង សម្តែងនូវសេចក្តីស្រឡាញ់រាប់អានរវាងគ្រូបង្រៀន រវា-ងគ្រូនិងសិស្ស និងរវាងសិស្សគ្នា ទៅវិញទៅមក ត្រូវបានគេគោរព លើកស្ទួយគ្រប់កាលវេលា។




ដើម្បីឆ្លើយតបតម្រូវការ និងស្តង់ដានៃការសិក្សាអប់រំបែបសម័យទំនើប ដើម្បីសម្តែងនូវសេចក្តីគោរពគាំទ្រចំពោះគម្រោង "សាលារៀនសុភមង្គល"។ ដូច្នេះ រសៀលថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥ សាលាវិទ្យាល័យអន្តេវាសិកជនជាតិ ហ្វិញគឿង និងក្រុមកងចំណាន Big Vision Media បានរួមចាត់តាំងឡើងនូវកម្មវិធី "អគ្គរដ្ឋទូតស្វូបភី" (Đại sứ Shoppe) ព្រមទាំងមានការចូលរួមនៃ ០២ អង្គភាពសាលាដែលមានទីតាំងនៅលើតំបន់ភូមិភាគខេត្តសុកត្រាំងទៀតផង នោះគឺសាលាអនុវិទ្យាល័យ - វិទ្យាល័យអន្តេវាសិកជនជាតិ ថាញ់ភូ និងសាលាវិទ្យាល័យ តឺនថាញ់។

គោលដៅចម្បងនៃគម្រោង "សាលារៀនសុភមង្គល" គឺកសាងក្របខ័ណ្ឌអប់រំដ៏ទូលំទូលាយ រួមបញ្ចូលគ្នានូវចំណេះដឹង និងការអភិវឌ្ឍន៍សង្គម សតិអារម្មណ៍ ដើម្បីជួយសិស្សានុសិស្សអភិវឌ្ឍយ៉ាងពេញលេញនូវសក្តានុពលរបស់ពួកគេ។







កម្មវិធីនេះ បានផ្តោតលើធាតុសំខាន់ៗនៅក្នុងជីវិតសាលារៀន គឺការថែរក្សាខ្លួនឯង ការអភិវឌ្ឍន្ទូវចំណេះដឹងដោយខ្លួនឯង ការថែទាំខ្លួនឯង ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ការកសាងទំនាក់ទំនងប្រកបដោយសុខដុមរមនា និងមានអត្ថន័យនៅក្នុងសហគមន៍ ថែរក្សាបរិស្ថាន អប់រំសិស្សឱ្យគោរព និងការពារធម្មជាតិ។ គម្រោងនេះមិនត្រឹមតែមានគោលបំណងអភិវឌ្ឍចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងជួយសិស្សានុសិស្សបង្កើនជំនាញជីវិត ជាពិសេសជំនាញសង្គម សតិអារម្មណ៍។

ការបង្កើត “សាលារៀនសុភមង្គល” មិនមែនជាកាតព្វកិច្ចរបស់សាលាតែមួយប៉ុណ្ណោះទេ គម្រោងនេះ នៅទាមទារកិច្ចសហការយ៉ាងជិតស្និទ្ធរវាងគ្រូបង្រៀន សិស្សានុសិស្ស និងមាតាបិតា។ កិច្ចសហការនេះ នឹងបង្កើតនៅបរិយាកាសអប់រំវិជ្ជមាន ដែលមនុស្សគ្រប់គ្នាសុទ្ធតែមានអារម្មណ៍ថាត្រូវបានស្រឡាញ់ មានសុវត្ថិភាព និងមានការគោរពគ្នាទៅវិញទៅមក៕